# ផែនទីរបស់
# កូនខ្ញុំទៅកាន់
# សេវាកម្មនានា





បិទរូបថតក្មេងត្រង់នេះ



យើងសង្ឃឹមថាកូនសៀវភៅនេះនឹងជួយគាំទ្រអ្នក ក្នុងដំណើរជីវិតអ្នកជាមួយកូនរបស់អ្នក។ ជូនកាល បន្ទាប់ពីទទួលរោគវិនិច្ឆ័យនៃជំងឺអូទីស្សឹម ឬការយឺតយ៉ាវនៃការអភិវឌ្ឍន៍ផ្នែកដ៏ទៃៗទៀត មាតា បិតាតែងតែភាន់ច្រឡំអំពីថាតើត្រូវធ្វើអ្វីបន្ទាប់ទៀត ។ កូនសៀវភៅនេះនឹងជួយអ្នកឲ្យដឹងថាតើត្រូវ ទាក់ទងទៅនរណា ហើយតើត្រូវចាប់ផ្តើមរកការជួយរបៀបណាសំរាប់កូនរបស់អ្នក?

*បានបង្កើតឡើងដោយក្រសួងសុខាភិបាលកុមាររដ្ឋវ៉ាស៊ីនតោន ជាមួយនិងកម្មវិធីត្រូវការថែទាំសុខភាពពិសេស និង ត្រូវបានជួយជម្រុញដោយស្នាដៃដ៏អស្ចារ្យរបស់អ្នកស្រី* **Katrina Davis –**

# ការធានារ៉ាប់រងសុខភាព
# និងម៉េឌីឃែរ

ក្រុមហ៊ុនធានារ៉ាប់រងសុខភាព ឬលេខប័ណ្ណវេជ្ជសាស្ត្រ (medical coupon) របស់កូនខ្ញុំគឺ:

______________________________________________

លេខទូរស័ព្ទ ______________________________________

អាសយដ្ឋាន ______________________________________

លេខប័ណ្ណសន្យារ៉ាប់រងរបស់កូនខ្ញុំគឺ: ____________________________

ប័ណ្ណសន្យារ៉ាប់រងរបស់កូនខ្ញុំគ្រប់គ្រងលើ (សូមអានទំព័រទី 7 សំរាប់ព័ត៌មានច្រើនថែមទៀតអំពីវិធីព្យាបាលទាំងនោះ)

__________ ម៉ោងព្យាបាលជំងឺវិជ្ជាជីវៈក្នុង ____________________

__________ ម៉ោងព្យាបាលកាយហាត់ក្នុង ____________________

__________ ម៉ោងព្យាបាលផ្នែកនិយាយក្នុង ____________________

វេជ្ជបណ្ឌិតកូនរបស់ខ្ញុំគឺ: ________________________________

លេខទូរស័ព្ទ: ______________________________________

ទំនាក់ទំនង: ______________________________________

បើសិនជាអ្នកមិនមានការធានារ៉ាប់រងសុខភាពសំរាប់កូនរបស់អ្នកទេ សូមទាក់ទងបណ្តាញទូរស័ព្ទពិសេសផ្នែកសុខភាពគ្រួសារតាមលេខ 1-800-322-2588 ឬចូលទស្សនាទំព័រវ៉ិបសាយឈ្មោះ Parent Help 123 តាមអាសយដ្ឋាន www.ParentHelp123.org។

ទីភ្នាក់ងារផ្នែកបញ្ជូនព័ត៌មានដែលឆ្លើយសំណួរតាមបណ្តាញទូរស័ព្ទពិសេសផ្នែកសុខភាពគ្រួសារមានការហ្វឹកហ្វឺនត្រឹមត្រូវដើម្បីជួយគ្រួសារក្នុងការដាក់ពាក្យសុំសំរាប់ការធានារ៉ាប់រងវេជ្ជសាស្ត្រ ហើយជួយរកប្រភពធនធាននានាផ្សេងៗទៀត ។ បណ្តាញទូរស័ព្ទពិសេសនេះមានបំរើបុគ្គលិកនិយាយភាសាអង់គ្លេស និងអេស្ប៉ាញ៉ុល ។ គេក៏មានចុះកិច្ចសន្យាជាមួយបណ្តាញ អ្នកបកប្រែសំរាប់ភាសាផ្សេងៗច្រើនទៀត ។

ទោះបីជាអ្នកមានការធានារ៉ាប់រងឯកជនហើយក៏ដោយ គ្រួសារអ្នកប្រហែលមានលក្ខណសម្បត្តិសំរាប់ជំនួយបន្ថែមពីរដ្ឋ ។ ការនេះប្រហែលអាចជួយសំរាប់ការបង់ថ្លៃរង និងការចំណាយចេញពីហោប៉ៅផេងៗទៀតបានដែរ ។

# អន្តរាគមន៍ជាបឋម

**សំរាប់កុមារក្រោមបីឆ្នាំ**

បើសិនជាកូនរបស់អ្នកមានអាយុក្រោមបីឆ្នាំ សូមទាក់ទងមកបណ្តាញពិសេសផ្នែកសុខភាពគ្រួសារ តាមលេខ 1-800-322-2588 និងសួររកឈ្មោះ ហើយនិងទំនាក់ទំនងសំរាប់ មេក្រុមនៃអ្នកសម្របសម្រួលធន ធានគ្រួសារ (FRC) នៅក្នុងតំបន់អ្នក ។ ការទូរស័ព្ទហៅមក មេក្រុមនៃអ្នកសម្របសម្រួលធនធាន គ្រួសារនឹងចាប់ផ្តើមដំណើរការដែលនាំឱយដឹងថាតើកូនរបស់អ្នកមានលក្ខណសម្បត្តិសំរាប់សេវា ជួយអន្តរាគមន៍ជាបឋមដែរ ឬទេ ។

មេក្រុមនៃអ្នកសម្របសម្រួលធន ធានគ្រួសារសំរាប់តំបន់ខ្ញុំគឺ:

ឈ្មោះ ______________________________

លេខទូរស័ព្ទ ______________________________

# ការអប់រំ

**សំរាប់កុមារបីឆ្នាំ ឬចាស់ជាង**

បើសិនជាកូនរបស់អ្នកមានអាយុបីឆ្នាំ ឬចាស់ជាង សូមទាក់ទងមកមណ្ឌលសិក្សាធិការតាមតំបន់ របស់អ្នក ហើយសួរគេនូវរបៀបសុំធ្វើការវាយតំលៃកូនរបស់អ្នក ។ បើអ្នកមិនដឹងឈ្មោះសាលាតាម តំបន់របស់អ្នកទេ សូមទាក់ទងមកបណ្តាញពិសេសផ្នែកសុខភាពគ្រួសារ តាមលេខ 1-800-322-2588 ឬចូលទស្សនាទំព័រវ៉ិបសាយ តាមអាសយដ្ឋាន www.ParentHelp123.org។

សាលាតាមមូលដ្ឋានគឺ:

ឈ្មោះសាលា ______________________________

ទំនាក់ទំនង ______________________________

លេខទូរស័ព្ទ ______________________________

**សិទ្ធិអប់រំរបស់កូនអ្នក**

ច្បាប់សហព័ន្ធដែលមានចំណងជើងថា ច្បាប់អប់រំសំរាប់បុគ្គលមានពិការភាព (IDEA) ធានាអះអាងថាកុមារម្នាក់ដែលមានលក្ខណសម្បត្តិផ្នែកការឃើតយ៉ាវនៃការអភិវឌ្ឍន៍នឹងទទួលការអប់រំ ដោយឥតបង់ថ្លៃ និងសមរម្យនៅក្នុងប្រព័ន្ធសាលាសាធារណៈ ចាប់ផ្តើមនៅអាយុ 3 ឆ្នាំ ។ ដើម្បីស្វែងយល់ថែមទៀតអំពី IDEA សូមទស្សនាទំព័រវ៉ឹបសៃយ៍ http://idea.ed.gov/។

# ក្រសួងផ្នែកពិការភាព
# នៃការអភិវឌ្ឍន៍ (DDD)

កូនរបស់អ្នកប្រហែលមានលទ្ធភាពទទួលសេវាកម្មពិសេសពីក្រសួងផ្នែកពិការភាពនៃការអភិវឌ្ឍន៍ ។ ទូរស័ព្ទមកលេខ **1-800-737-0617** ឬអញ្ជើញទស្សនាទំព័រវ៉ិបសៃយ៍នេះ **www.dshs.wa.gov/DDD/contacts.shtml** ដើម្បីស្វែងរកការិយាល័យនៅក្នុងតំបន់អ្នក ។

ក្រោយពីអ្នកដាក់ក្រដាសស្នាមសុំជួបប្រជុំជាមួយគេមួយទល់មួយ ហើយនិង **"ការវាយតំលៃតាមកុំព្យូទ័រ"** រួចហើយ សួរគេឱយដឹងថាតើកូនរបស់អ្នកនឹងទទួល:

- **ការមើលថែរទាំជំនួសម្តងម្កាល** (ការនេះគឺនៅពេលដែលជនមានសញ្ញាប័ត្រជួយមើលថែទាំកូនរបស់អ្នកដើម្បីឱយអ្នកមានឱកាសសំរាក)
- មូលនិធិគាំទ្រគ្រួសារ
- ការមើលថែទាំផ្ទាល់ខ្លួនផ្នែកវេជ្ជសាស្រ្ត

ឈ្មោះការិយាល័យ DDD តាមតំបន់ ____________________

ឈ្មោះជនត្រូវទាក់ទង ឬនាយកចាត់ចែងសំណុំរឿង ____________________

លេខទូរស័ព្ទ ____________________

សួរនាយកចាត់ចែងសំណុំរឿងកម្មវិធី DDD របស់អ្នក បើកូនរបស់អ្នកមានគុណសម្បត្តិសំរាប់ការធានារ៉ាប់រងសន្តិសុខសង្គម ។

# ការថែទាំកុមារ

បើកូនរបស់អ្នកចូលទទួលការថែទាំនៅមណ្ឌលទារកកដ្ឋាន និយាយជាមួយនាយកមើលខុសត្រូវមណ្ឌល អំពីរបៀបដែលបុគ្គលិកអាចជួយថែទាំកូនរបស់អ្នកបានប្រសើរបំផុត ។ អ្នកអាចស្នើសុំឱយបុគ្គលិកខាងអន្តរាគមន៍ជាបឋម ឬបុគ្គលិកមណ្ឌលសិក្សាធិការឱយផ្តល់ការអប់រំពិសេសនៅតាមមណ្ឌលសំរាប់មនុស្សគ្រប់រូបដែលមានការប៉ះពាល់ជាមួយកូនអ្នក ។

បើអ្នកត្រូវការរកមណ្ឌលទារកកដ្ឋានសំរាប់កូនរបស់អ្នក សូមទូរស័ព្ទមកទីភ្នាក់ងារ ផ្នែកធនធានថែទាំកុមារ និងការបញ្ជូនតាមលេខ 1-800-446-1114 ឬទស្សនាទំព័រវ៉ិបសាយតាមអាសយដ្ឋាន www.childcarenet.org/។

មណ្ឌលទារកកដ្ឋាន ____________________

លេខទូរស័ព្ទ ____________________

ឈ្មោះនាយកមលខុសត្រូវ ____________________

ឈ្មោះគ្រូបង្រៀន____________________

# ការគាំទ្រគ្រួសារ

រដ្ឋវ៉ាស៊ីនតោនគឺមានភ័ព្វវាសនាណាស់ដែលបានបង្កើតអង្គការជួយគាំទ្រនានាទូទាំងរដ្ឋសំរាប់សហគមន៍ជាច្រើន ។ ការជួយគាំទ្រពីសំណាក់មាតាបិតាដែលកូនរបស់គេមានសេចក្តីត្រូវការពិសេស រួមទាំងវិបល្លាសវិសាលគមអូទីស្សឹម មានផលប្រយោជន៍ជាច្រើន ។ មាតាបិតា បងប្អូនបង្កើត ជីដូនជីតា និងសមាជិកគ្រួសារដ៏ទៃទៀតមានលទ្ធភាពជជែកពិភាក្សានូវសេចក្តីសង្ឃឹមរបស់គេ សុបិន ការភ័យខ្លាចនានា ជាដើម ជាមួយមនុស្សដែលមានស្ថានភាពស្រដៀងៗគ្នា ។

ជាបន្ថែមពីលើអង្គការនានាដែលមានរាយខាងក្រោម សូមសាកសួរជាមួយមន្ទីរពេទ្យតាមតំបន់របស់អ្នក ឬគិលានដ្ឋានវេជ្ជសាស្រ្តសំរាប់ការប្រជុំគាំទ្រទាំងឡាយដែលត្រូវការ ។

អ្នកអាចរកក្រុមគាំទ្រនានាជាមួយនឹង:

**មាតាបិតាទៅមាតាបិតា**
1-888-754-8798 ឬ www.arcwa.org/parent_to_parent.htm

**បណ្តាញបិតាទាំងពួង**
(425) 653-4286 ឬ www.fathersnetwork.org/

**ដៃគូសំរាប់សកម្មភាពសំឡេងសំរាប់ការជួយផ្តល់អានុភាព (PAVE)**
1-800-5-PARENT or www.wapave.org/

**សំឡេងគ្រួសារ**
(505) 872-4774 ឬ www.familyvoices.org/

# ការអប់រំមាតាបិតា

មាតាបិតាខ្លះៗមានអារម្មណ៍ពោរពេញដោយការរន្ធត់ជាមួយនឹងព័ត៌មានដែលគេមានអំពីវិបល្លាសនៃវិសាលគមអូទីស្សឹម ។ យើងបានប្រមូលផ្តុំ ប្រភពធនធានផ្តើមដំបូងមួយចំនួន ដើម្បីជួយអ្នកចាប់ផ្តើមស្វែងយល់ដឹងអំពីរោគវិនិច្ឆ័យរបស់កូនអ្នក ។

ទំព័រវិបសាយខាងក្រោមមានព័ត៌មានដែលប្រហែលមានប្រយោជន៍ដល់អ្នក:

www.autismspeaks.org

www.autism-society.org

www.autismsocietyofwa.org

www.autismoutreachproject.org

សមាគមអាខាដេមី អាមេរិកាំងនៃវិទ្យាពេទ្យកុមារបានបង្កើតកូនសៀវភៅមានចំណងជើង ***ការយល់ដឹងវិបល្លាសនៃវិសាលគមអូទីស្សឹម*** ។ សួរគ្រូពេទ្យកុមាររបស់កូនអ្នក ឬអ្នកផ្តល់ការបំរើវេជ្ជសាស្ត្រជាគោល បើអ្នកអាចខ្ចីសំណៅចំឡងពីគេមួយច្បាប់ ។

មន្ទីរពេទ្យជាច្រើន ព្រមទាំងសកលវិទ្យាល័យមានមុខវិជ្ជាសិក្សា Autism 101 ឬមុខវិជ្ជាស្រដៀងៗគ្នា ធម្មតាគេយកថ្លៃឈ្នួលកំរិតទាបទេ ។ ទូរស័ព្ទទៅមន្ទីរពេទ្យតាមស្រុករបស់អ្នក ដើម្បីសួរគេតើមានអ្វីសំរាប់សហាគមន៍របស់អ្នក ។

ក្រសួងសុខភិបាលក្នុងតំបន់មានអ្នកសម្របសម្រួលផ្នែកកុមារមានសេចក្តីត្រូវការថៃទាំសុខភាពពិសេសដែលប្រហែលដឹងប្រភពធនធាននានាបន្ថែមទៀតដើម្បីជួយអ្នក នឹងកូនរបស់អ្នក ។ រកទីតាំងក្រសួងសុខាភិបាលក្នុងសហាគមន៍របស់អ្នកតាមវិបសាយ
http://www.doh.wa.gov/cfh/mch/documents/coordlst.pdf

ខាងក្រោមនេះនឹងជួយអ្នកឱយទទួលបាននូវជំនាញនៃការជួយគាំទ្រសំរាប់កូនរបស់អ្នក:

**ដៃគូសំរាប់សកម្មភាពសំឡេងសំរាប់ការជួយផ្តល់អានុភាព (PAVE)**
1-800-5-PARENT ឬ www.washingtonpave.org/

**ការិយាល័យនៃអ្នកស៊ើបអង្កេតបណ្តឹងអប់រំ**
1-866-297-2597 *(អាចមានសេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ)* ឬ
www.governor.wa.gov/oeo/

**ការិយាល័យស្នងការនៃការអប់រំសាធារណ: (OSPI)**
(360) 725-6000 ឬ www.k12.wa.us/

# វិធីព្យាបាលនានាដែលមាន

**វិធីព្យាបាលជំងឺវិជ្ជាជីវៈ (OT)** - ជួយកុមារណាម្នាក់ដែលមានជំនាញឆាប់ដឹងផ្នែកចលនាតូចៗ និងចក្ខុវិញ្ញាណ ។ វិធីព្យាបាល OT អាចជួយកុមារម្នាក់រៀនលេងជាមួយល្បែងក្មេង ស្លៀកពាក់ ញ៉ាំអាហារ  លប់លាងមុខរបស់គេ សិតសក់របស់គេ និងប្រើបង្គន់ដោយឯករាជ្យ ។

**វិធីព្យាបាលកាយហាត់ (PT)** - ផ្តោតអារម្មណ៍លើការធ្វើឱយសាច់ដុំធំៗរបស់កុមារមានការប្រសើរឡើងហើយជួយកុមារក្នុងការអង្គុយ ដើរ រត់ នឹងចលនាប្រភេទផ្សេងៗទៀត ។

**វិធីព្យាបាលការនិយាយ និងភាសា (SLT)** - ជួយកុមារម្នាក់ឱយរៀននិយាយ ឬប្រើការទាក់ទងទម្រង់ផ្សេងៗទៀត រៀនជំនាញសង្គម ហើយប្រហែលអាចត្រូវបានប្រើដើម្បីជួយកុមាររៀនទំពារ ផឹក និងលេបអាហារ ។

(កណត់ហេតុ: កូនរបស់អ្នកប្រហែលមានលក្ខណសម្បត្តិសំរាប់វិធីព្យាបាល សំរាប់ជំងឺវិជ្ជាជីវៈ កាយហាត់ និងការនិយាយ តាមរយៈមណ្ឌលសិក្សាធិការ និងតាមរយៈការធានារ៉ាប់រងឯកជន ឬម៉េឌីខេដ) ។

**ការវិភាគលើចរិយាបានអនុវត្តិន៍ (ABA)** - គោលដៅរបស់វិធីព្យាបាល ABA គឺដើម្បីបង្កើនចរិយាសមរម្យ ហើយកាត់បន្ថយនូវចរិយាមិនសមរម្យនានា ។ ស្ទើរតែគ្រប់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងរដ្ឋវ៉ាស៊ិនតោនមិនមានគ្រប់គ្រងលើការព្យាបាល ABA នេះទេ ។ មនុស្សភាគច្រើនចេញថ្លៃចំណាយពីហោប៉ៅខ្លួនឯង បើគេចង់ឱយមានការព្យាបាល ABA សំរាប់កូនរបស់គេ ។ ជាធម្មតាអ្នកប្រឹក្សាទូន្មានរៀបចំ និងមើលខុសត្រូវលើកម្មវិធី ហើយអ្នកព្យាបាល ឬអ្នកបង្រៀនមួយទល់មួយ ផ្តល់ការព្យាបាលមួយទ័ល់មួយ ។
សិក្សាអំពីកម្មវិធីតាមផ្ទះផ្សេងៗទៀតដែលបានប្រើដោយមាតាបិតាផ្សេងៗទៀតនៅក្នុងវ៉ិបសាយ www.autismspeaks.org/whattodo/index.php។

**វិធីព្យាបាលបន្ថែម ឬបែបផ្សេង** - មាតាបិតាជាច្រើនប្រើវិធីព្យាបាលបែបផ្សេង ឬបន្ថែម ទាំងស្រែងបាន ឬក៏ក្នុងការបន្ថែមពីលើការព្យាបាលវេជ្ជសាស្ត្រ និងការអប់រំក៏បាន ។ បើសិនជាកូនរបស់ អ្នកទទួលការព្យាបាលពីអ្នកផ្តល់ការបំរើវេជ្ជសាស្ត្របឋម មួយដូចជាគ្រូពេទ្យកុមារ ឬអ្នកព្យាបាលរោគដោយធម្មជាតិ ជាការសំខាន់ដែលអ្នកពិគ្រោះនូវការប្រើរបៀបតមអាហ៊ារ តិណជាតិ វីតាមីនបន្ថែម ឬក៏ការព្យាបាល របៀបផ្សេងណាមួយ ជាមួយគេផងដែរ ។ ផលិតផលទិញបានតាមផ្ទើរខ្លះៗអាចមានផលប៉ះពាល់គ្រោះថ្នាក់ធ្ងន់ធ្ងរ ជាពិសេសសំរាប់កុមារ ។

ផែនការធានារ៉ាប់រងរបស់កូនខ្ញុំ គ្រប់គ្រងសំរាប់ការព្យាបាលរបៀបផ្សេងទៀតដូចខាងក្រោមនេះ៖

________________________________________

________________________________________

________________________________________

ខ្ញុំ ❒ ត្រូវការ    ❒ មិនត្រូវការ   ការបញ្ជូនសំរាប់សេវានេះ ។

មានព័ត៌មានជាច្រើនមាននៅតាម តាមសៀវភៅ និងតាមទូរទស្សន៍អំពីរបៀប “ព្យាបាល” ជំងឺអូទីស្សិមរបស់កូនអ្នក ។ ខណៈដែលជាសិទ្ធិរបស់មាតាបិតា ហើយប្រហែលជាករណីកិច្ចធ្វើការស៊ើបអង្កេតគ្រប់ការព្យាបាលទៀតផង សូមឱយដឹងថាគ្មានការស្រាវជ្រាវវិទ្យាសាស្ត្រ ឬភ័ស្តុតាងណាមួយដែលអាចព្យាបាលកុមារណាម្នាក់ឱយជាពីអូទីស្សិម អ្វីឡើយ ។

# បញ្ជីថ្នាំព្យាបាលរបស់កូនខ្ញុំ

ឈ្មោះថ្នាំព្យាបាល កំរិតដូស ពេល ______________________________
តើនរណាចេញវេជ្ជបញ្ជា? ______________________________
សំរាប់ព្យាបាល ______________________________
ថ្នាំត្រូវការបំពេញឡើងវិញនៅ ______________________________
បញ្ហា /ផលប៉ះពាល់នានា ______________________________

ឈ្មោះថ្នាំព្យាបាល កំរិតដូស ពេល ______________________________
តើនរណាចេញវេជ្ជបញ្ជា? ______________________________
សំរាប់ព្យាបាល ______________________________
ថ្នាំត្រូវការបំពេញឡើងវិញនៅ ______________________________
បញ្ហា /ផលប៉ះពាល់នានា ______________________________

ឈ្មោះថ្នាំព្យាបាល កំរិតដូស ពេល ______________________________
តើនរណាចេញវេជ្ជបញ្ជា? ______________________________
សំរាប់ព្យាបាល ______________________________
ថ្នាំត្រូវការបំពេញឡើងវិញនៅ ______________________________
បញ្ហា /ផលប៉ះពាល់នានា ______________________________

ឈ្មោះថ្នាំព្យាបាល កំរិតដូស ពេល ______________________________
តើនរណាចេញវេជ្ជបញ្ជា? ______________________________
សំរាប់ព្យាបាល ______________________________
ថ្នាំត្រូវការបំពេញឡើងវិញនៅ ______________________________
បញ្ហា /ផលប៉ះពាល់នានា ______________________________

# តម្រុយណែនាំសំខាន់ៗ

- ♥ បើសិនជាកូនរបស់អ្នកមានការធានារ៉ាប់រងឯកជន នេះជាប្រភពគ្រប់គ្រងជាចំបងតែមួយ ។ ក្លាយជាអ្នកឯកទេសនៅក្នុងប័ណ្ណធានារ៉ាប់រងរបស់កូនអ្នក ។ ការយល់ដឹងប័ណ្ណធានារ៉ាប់រងរបស់អ្នកជាការសំខាន់ណាស់ ។

- ♥ បើសិនជាវិក័យប័ត្រថ្លៃពេទ្យរបស់កូនអ្នកមិនមានគ្រប់គ្រងដោយផែនការធានារ៉ាប់រងណាមួយទេ មន្ទីរពេទ្យ និងអ្នកផ្តល់ការបំរើ ដ៏ទៃទៀតប្រហែលចរចាបន្ថយ ឬពន្យាការបង់ថ្លៃ ។ អ្នកប្រហែលត្រូវការនិយាយជាមួយអ្នកផ្តល់ការបំរើនិមួយៗសំរាប់វិកយប័ត្រនៃសេវាដែលគេផ្តល់ជូន ។

- ♥ រក្សាបញ្ជីទូរស័ព្ទហៅទាំងអស់ ការអញ្ជើញទៅជួបវេជ្ជបណ្ឌិត ព័ត៌មានទាក់ទងនាយកដ្ឋានអភិវឌ្ឍន៍ផ្នែកពិការភាព (DDD) ក្រដាសស្នាមអំពីការធានារ៉ាប់រង លិខិតជូនដំណឹងនានា ការប្រស្រ័យទាក់ទងជាមួយសាលា និងទម្រង់ផ្សេងៗដែលទាក់ទងនឹងកូនរបស់អ្នក ។

- ♥ អ្នកអាចស្នើសុំឧបករណ៍រៀបចំការថែទាំ ដោយឥតគិតថ្លៃដោយទូរស័ព្ទមកលេខ 206-884-5735 ឬទស្សនាវីបសៃយ៍ http://cshcn.org/care-notebook-and-care-organizer-order-form

- ♥ គ្រួសារកុមារជាច្រើនដែលមានសេចក្តីត្រូវការផ្នែកថែទាំសុខភាពចំណាយពេលច្រើនអស្ចារ្យណាស់ដើម្បីសម្របសម្រួលការថែទាំសុខភាពសំរាប់កូនរបស់គេ ។ ការនេះអាចបង្កើតនូវការធុញថប់អារម្មណ៍សំរាប់អ្នកក្នុងតំបន់ជាច្រើន ។ សួរវេជ្ជបណ្ឌិតរបស់កូនអ្នក គ្រូបង្រៀន អ្នកព្យាបាល នឹងជននានាដែលទាក់ទងនឹងការមើលថែទាំកូនរបស់អ្នកឱយគេជួយ ។

- ♥ ត្រូវចងចាំបន្តសកម្មភាពកំសាន្តនានាដូចជាការហាត់ប្រាណ ឬការធ្វើភាវនា បរិភោគចំណីអាហារមានសុខភាព និងសំរាកឱយបានច្រើនបើអាចធ្វើបាន ។

សំរាប់សំណួរ ឬយោបល់ផ្សេងៗ សូមទាក់ទងមកអ្នកស្រី Susan Ray, អ្នកសម្របសម្រួលផ្នែកការពាក់ព័ន្ធគ្រួសារ តាមលេខ (360) 236-3504 ឬអ៊ីម៉ែល susan.ray@doh.wa.gov។

សំរាប់ជនដែលមានពិការភាព ឯកសារនេះអាចមានជូនបានតាមការស្នើសុំ ជាទម្រង់ផ្សេងៗទៀត ។ ដើម្បីដាក់ពាក្យស្នើសុំ សូមទូរស័ព្ទមកលេខ 1-800-525-0127 (TDD/TTY 1-800-833-6388)។

.

ការបោះពុម្ពផ្សាយនេះត្រូវបានផ្តល់មូលនិធិដោយក្រសួងសុខាភិបាលកុមាររដ្ឋវ៉ាស៊ីនតោន និងកម្មវិធី
ត្រូវការថែទាំសុខភាពពិសេស តាមរយៈ "ការដឹងពីជំងឺអូទីស្សឹមៈ ដៃគូសំរាប់ការផ្លាស់ប្តូរ" មូលនិធិ
(H6MMC11065) ពីក្រសួងសុខាភិបាល និងមនុស្សកិច្ច ស.រ
ធនធានសុខាភិបាល និងអភិបាលកិច្ចសេវាកម្ម ការិយាល័យសុខភាពមាតា និងកុមារ ។

ការបោះពុម្ពផ្សាយលេខ DOH: 970-138

**មណ្ឌលព័ត៌មានសុខភាព ពីគ្រួសារ ទៅគ្រួសារ របស់**

**PAVE**

**សម្លេងគ្រួសារនៃរដ្ឋវ៉ាស៊ីន**

ការបកប្រែ និងការបោះពុម្ព ការផ្សាយនេះគឺត្រូវបានផ្តល់មូលនិធិដោយធនធានសុខាភិបាល និងអភិបាលកិច្ចសេវាកម្ម
(HRSA)/ ការិយាល័យសុខភាពមាតា និងកុមារ (MCHB)/
នាយកដ្ឋានផ្នែកសេវាកម្មសំរាប់កុមារមានការត្រូវការពិសេស (DSCSHN) តាមរយៈមូលនិធិលេខ #H84MC09369

*នេះជាបទបញ្ជាផ្ទៃក្នុងរបស់ PAVE ដែលថា គ្រប់កម្មវិធីទាំងអស់ ការអនុវត្តន៍ការងារ និងសកម្មភាពនានារបស់ អង្គការ ឬសកម្មភាព របស់អ្នកមៅការរបស់គេ អ្នកលក់ អនុប្បទានិក ឬអ្នកស្ម័គ្រចិត្ត នឹងត្រូវធ្វើឡើងដោយមិនគិតពីពូជសាសន៍របស់ជនណាម្នាក់ ព័ណ៌សម្បុរ សញ្ជាតិដើម លក្ខណអាពាហ៍ពិពាហ៍ ពិការ ឬមានឋានៈជាអតីត យុទ្ធជនជំនាន់វៀតណាម ភេទ សាសនា គោលជំនឿ អាយុ ចំណង់ចំណូលចិត្តផ្លូវភេទ ភេគហីវ/*អេដ្សដ៏ ឬវណ្ណត្រូវបានការពារដ៏ទៃៗទៀត ។